## ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ១៨៣ II ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣

**ពាក្យគន្លឹះ៖** ទម្រង់ទទួលខុសត្រូវ (សមគំនិត) ធាតុផ្សំនៃទម្រង់ទទួលខុសត្រូវ បទជួញដូរសារធាតុញៀន

### ១. អង្គហេតុនិងនីតិវិធី

អង្គហេតុបានកើតក្នុងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០ នៅក្រុងព្រះសីហនុ។ **ហួសានី** ជាជនសង្ស័យម្នាក់ត្រូវបានឃាត់ខ្លួន ក្រោយពេលចាប់បានជនល្មើស ដែលបានអះអាងថា **ហួសានី** បានឲ្យលេខទូរស័ព្ទនៃអ្នកលក់ ហើយគាត់បានទាក់ទងទិញដើម្បីជួញដូរ (មេតំហ្វេតាមីន ៩៥ក្រាម)។ **ហួសានី** ត្រូវបានផ្តន្ទាទោស ៥ឆ្នាំដាក់ពន្ធនាគារដោយសាលាដំបូង តាមអំណាចសាលក្រមលេខ៤២៤/៤៥ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ ២០២១។ សាលាឧទ្ធរណ៍ តាមសាលដីកាលេខ១១៥៣/១៩ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២១ ដោយតម្កល់សាលក្រម។ **ហួសានី** មិនពេញចិត្ត បានប្តឹងសាទុក្ខមកកំពូល។ តុលាការកំពូល បានបើកសវនាការក្នុងថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ និងបានចេញសាលដីកាលេខ១៨៣II ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣។

ក្នុងពេលសវនាការ មេធាវី បានព្យាយាមបង្ហាញថា ការដាក់ទោស ដោយគ្រាន់តែ **ហួសានី** ផ្តល់លេខទូរស័ព្ទទៅចារី យូរខែមុនការទិញសារធាតុញៀន ដោយមិនដឹងច្បាស់ថា ចារីប្រើលេខដើម្បីទូរស័ព្ទជាជនសមគំនិត មិនមានសំអាងហេតុគ្រប់គ្រាន់ (គ្មានសំអាងហេតុក្នុងមាត្រា៤១៩) និងបានស្នើសុំឲ្យតុលាការកំពូលបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍វិញ។

### ២. កំណត់សំគាល់និងយោបល់

**ក.** ចាប់ពីថ្ងៃកើតហេតុ មកដល់ថ្ងៃសវនាការដោយតុលាការកំពូល មានរយៈពេលជិត៣ឆ្នាំ (លឿនឆាប់ ប្រសិនបើធៀបនឹងសំណុំរឿងដទៃទៀត)។

**ខ.** សាលាជាន់ទាប និងតុលាការកំពូលដែលតម្កល់សាលដីកា ដាក់ទោសចារី៨ឆ្នាំ (បទជួញដូរ) និង ៥ឆ្នាំ (បទសមគំនិតជួញដូរសារធាតុញៀន) ទោះបីច្បាប់កំណត់ថា ចារីនិងជនសមគំនិតមានទោសដូចគ្នា (មាត្រា២៩នៃក្រមព្រហ្មទណ្ឌ)។

**គ.** ក្នុងសំណុំរឿងនេះ តុលាការកំពូលបានផ្តល់ទស្សនះល្អជាច្រើនអំពីធាតុផ្សំនៃទម្រង់ទទួលខុសត្រូវសមគំនិត៖ **១.** អ្វីដែលសំខាន់គឺចេតនាទុច្ចរិតក្នុងការជួយឲ្យបទល្មើសប្រព្រឹត្តដោយចារី។ **២.** ទង្វើជួយ (ផ្តល់

លេខទូរស័ព្ទ) មិនចាំបាច់ឆាប់ឬយូរមុនពេលសកម្មភាពចារីប្រព្រឹត្តទេ (យកលេខទៅតែដើម្បីទិញសារធាតុញៀន)។ ៣. វាមិនសំខាន់ថាជនសមគំនិតបានប្រយោជន៍ពីទង្វើជួយរបស់ខ្លួនទេ និងទី៤. ជនសមគំនិតមិនចាំបាច់ស្គាល់ចារីផងដែរ (ទំ.១០)។

ក្រមព្រហ្មទណ្ឌមាត្រា ២៩ មិនបានចែងអំពីធាតុផ្សំនៃការសមគំនិតទេ។ សាលដីកានេះ បានជួយបំភ្លឺជាលម្អិត។ អ្វីដែលកត់សំគាល់បន្ថែមគឺចំណុចទី៤ ដែលអាចនិយាយថា តុលាការកំពូលបានបន្ថែមធាតុផ្សំថ្មីមួយនៃទម្រង់ទទួលខុសត្រូវប្រភេទនេះ។ យុត្តាធិការខ្លះ តម្រូវបញ្ជាសមកវិញថា ចារីមិនចាំបាច់ស្គាល់ជនសមគំនិត ដើម្បីឲ្យទង្វើជួយរបស់ជននោះទទួលខុសត្រូវទេ។ ចំណុចទី៤ ជាធាតុផ្សំថ្មីក៏ប៉ុន្តែ មិនមានមូលដ្ឋានរឹងមាំដោយសារថា ជនសមគំនិតត្រូវតែដឹងបទល្មើស ដែលចារីនឹងប្រព្រឹត្ត (មិនចាំបាច់ដឹងលម្អិតឬជាក់លាក់ទេ) ដូចនេះចង់ឬមិនចង់ ជនសមគំនិតអាចនឹងស្គាល់ចារី។